# ព្រះរាជក្រឹត្យ

នស/រកត/០៦២៤/ ៥៧៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៨៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា១៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងមុខតំណែងឯកឧត្តម **នី គឹមសាន** ជាអនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ ។

**មាត្រា២** : តែងតាំងមុខតំណែងបន្ថែមជូនមន្ត្រីរាជការ ៤រូប ក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)៖

| | |
|---|---|
| ១- ឯកឧត្តម **ចាន់ សុធា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ២- ឯកឧត្តម **ឡាយ ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៣- ឯកឧត្តម **នី គឹមសាន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៤- ឯកឧត្តម **ម៉ាឡេន ម៉ារូណាត** | ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |

| | |
|---|---|
| ៥- ឯកឧត្តម **ឈុន ម៉ុនណារ៉ា** | ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៦- ឯកឧត្តម **ឆេង ខឡុន:** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៧- ឯកឧត្តម **ស៊ិន ស៊ុនសុភក្តិ** | ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៨- ឯកឧត្តម **ទឹម សំអែល** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ជាប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប.។ |

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

នរោត្តម សីហមុនី

៣៧៧.៤៤០៦.៥៧៥

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០២៤

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**